# និន្នាការសេដ្ឋកិច្ចសង្គម

## Socio-Economic Trends

### ប្រចាំខែ តុលា-វិច្ឆិកា ឆ្នាំ២០១៥/October-November,2015

**ខ្លឹមសារសង្ខេប/Executive summary**

១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញក្នុងខែវិច្ឆិកា ឆ្នាំ២០១៥ បានថយចុះចំនួន ០,២ ភាគរយ ធៀបនឹងខែមុន ប៉ុន្តែបានកើនឡើង ១,៩ ភាគរយ ធៀបទៅនឹង១២ខែមុន ។សន្ទស្សន៍ ថ្លៃទំនិញប្រើប្រាស់សរុបប្រចាំឆ្នាំ បានធ្លាក់ចុះទាបគិតមកត្រឹមខែវិច្ឆិកា នេះ ប៉ុន្តែ បើមិនគិតសន្ទស្សន៍ថ្លៃក្រុមទី៤ និងទី៧ ដែលពាក់ព័ន្ធទៅនឹងការចុះថ្លៃប្រេងឥន្ធនៈដ៏គំហុកនោះ គឺសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់សរុបប្រចាំឆ្នាំ មានកំណើនធំជាងចំនួន ៤ ភាគរយ ។ កត្តានេះ មកពីការកើនឡើងសន្ទស្សន៍ថ្លៃម្ហូបអាហារនិងសន្ទស្សន៍ថ្លៃភោជនីយដ្ឋាន ដែលបណ្តាលមកពីការថយចុះផលនេសាទ ការផ្ទុះជម្ងឺឆ្លងក្នុងវិស័យបសុសត្វ និងការដាំដុះបន្លែបង្ការក្នុងស្រុកទទួលបានទិន្នផលទាប មកពីអាកាសធាតុមិនសូវអំណោយផលល្អ។ តាមការសង្កេតនិន្នាការសន្ទស្សន៍ថ្លៃម្ហូបអាហារ និងសន្ទស្សន៍ថ្លៃភោជនីយដ្ឋានមានកំណើនខ្ពស់ជាងគេ បើប្រៀបធៀបទៅនឹងសន្ទស្សន៍ថ្លៃទំនិញផ្សេងៗទៀត ។

២. គិតត្រឹមខែតុលា ឆ្នាំ២០១៥ នេះរូបិយវត្ថុទូទៅ (M2) សម្រេចបាន ៤៧ ៤៥២ ប៊ីលានរៀល គឺបានកើនឡើងចំនួន ១,១ភាគរយ ធៀបទៅនឹងខែមុន ឬ ១៥,៣ ភាគរយ ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ដោយសារការកើនឡើងរូបិយវត្ថុផ្សេងៗ (Quasi-Money) ជាពិសេសប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស ប៉ុន្តែរូបិយវត្ថុ (M1) បានធ្លាក់ចុះចំនួន០,៥ភាគរយ ធៀបនឹងខែមុន ដោយសារការធ្លាក់ចុះរូបិយវត្ថុក្រៅធនាគារ

។ទន្ទឹមនឹងនេះ ចំនួនប្រាក់បញ្ញើមានកាលកំណត់និងសន្សំជាប្រាក់រៀលរបស់ធនាគារពាណិជ្ជ បានធ្លាក់ចុះ ដោយសារប្រាក់ដុល្លារនៅតែមានចំនួនច្រើននៅលើទីផ្សារ។

៣. រយៈពេល១០ខែឆ្នាំ ២០១៥ តម្លៃនាំចូលទំនិញសរុបជាទឹកប្រាក់មានចំនួន ៩,៦២ ប៊ីលានដុល្លារ កើនឡើងប្រមាណ ១៤ ភាគរយ ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ។ ការនាំចូលវត្ថុធាតុដើមសម្រាប់ផលិតផលវាយនភ័ណ្ឌ មានចំណែកធំជាងគេបន្ទាប់មកបរិក្ខាសំណង់ គ្រឿងយន្ត និងប្រេងឥន្ធនៈ។ តាមការសង្កេត តម្រូវការកន្លងមកមានសន្ទុះកើនឡើងខ្លាំងនិងនៅតែបន្តទាំងផ្នែកផលិតកម្ម និងការប្រើប្រាស់ប្រចាំថ្ងៃ។ ចំពោះការនាំចេញសរុប សម្រេចបានចំនួន ៧,៦៩ ប៊ីលានដុល្លារ គឺបានកើនឡើងប្រមាណជា ១៤ ភាគរយ ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។ ការនាំចេញផលិតផលកាត់ដេរនិងស្បែកជើងនៅតែរក្សាបានចំណែកធំជាងគេបន្ទាប់មកមានអង្ករ និងកៅស៊ូ ជាដើម ក្នុងការគាំទ្រកំណើនសេដ្ឋកិច្ច ។

៤. រយៈពេល១០ខែដើមឆ្នាំ២០១៥ នេះ ចំណូលក្នុងស្រុកអនុវត្តបានចំនួន ៩.៨៤៨,៥ ពាន់លានរៀលគឺខ្ពស់ជាង៥,០ ភាគរយ នៃច្បាប់ថវិកាសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនិងបានកើនឡើង១៦,១ ភាគរយបើធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុនក្នុងនោះចំណូលពីអគ្គនាយកដ្ឋានពន្ធដារបានកើនឡើង ២៣,២ ភាគរយ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាបានកើនឡើង ១៥,០ ភាគរយ។ ចំណែកឯការអនុវត្តចំណាយសរុបសម្រេចបានចំនួន ៨.២៥២,៦៧ ពាន់លានរៀល គឺទាបជាង ២៦,៨ ភាគរយនៃច្បាប់ថវិកាសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ឬថយចុះ ១៥,៨៧ ភាគរយ ធៀបទៅនឹងរយៈពេលដូចគ្នាក្នុងឆ្នាំមុន។ លទ្ធផលនៃការប្រមូលចំណូលនៅឆ្នាំ២០១៥នេះប្រព្រឹត្តទៅតាមការគ្រោងទុក។ ចំណែកភាពយឺតយ៉ាវខាងផ្នែក

ចំណាយ តាមការសង្កេត បាននឹងកំពុងកែលំអនៅក្នុងការអនុវត្តត្រីមាសទី៤ដោយសារការយល់ដឹងកាន់តែប្រសើរឡើងអំពីនីតិវិធីហិរញ្ញវត្ថុដែលបានដាក់ចេញកាលពីដើមឆ្នាំកន្លងទៅ។

៥. រយៈពេល១០ខែ ឆ្នាំ២០១៥ នេះ សំណើសុំវិនិយោគសរុបទូទាំងប្រទេសមានចំនួន ១០៩ គម្រោង គឺថយចុះ ២៩ គម្រោង ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០១៤ កន្លងទៅ ប៉ុន្តែ គិតជាទុនវិនិយោគសរុបចំនួន ៣,៧ ប៊ីលានដុល្លារ គឺបានកើនឡើង ១៣១ភាគរយ ធៀបទៅនឹងរយៈពេលដូចគ្នាឆ្នាំ ២០១៤ ។ គម្រោងវិនិយោគធំៗមាន ដូចជា លើវិស័យកសិកម្ម សេវាកម្មនិងទេសចរណ៍ និង ឧស្សាហកម្ម ជាដើម ដែលគម្រោងទាំងនេះ អាចបង្កើតបានកំលាំងពលកម្មប្រមាណជា ១៣៦,១០ លាន នាក់ ។

៦. នៅខែតុលា ឆ្នាំ២០១៥ នេះ ភ្ញៀវទេសចរសរុបមានចំនួន ៤០៨,៩២ ពាន់ នាក់ បានកើនឡើង ៤,៦ ភាគរយ ធៀបនឹងខែដូចគ្នាឆ្នាំមុន គឺដោយសារការកើនឡើងអ្នកដំណើរតាមផ្លូវគោកនិងទឹក ពីព្រោះផ្លូវងាយស្រួលធ្វើដំណើរ និងសេវាកម្មមានភាពល្អប្រសើរជាងមុន ។ ក្នុងរយៈពេល១០ខែដើមឆ្នាំនេះ ភ្ញៀវទេសចរសរុបមានចំនួន ៣,៧៥ លាន នាក់ ឬ បានកើនឡើង ៤,៦ភាគរយ បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ ២០១៤ ។

៧. រយៈពេល១០ខែឆ្នាំ ២០១៥ នេះ សំណើសុំសាងសង់សរុបទូទាំងប្រទេសមានចំនួន ១.៦៥៦ គម្រោង គឺបានកើនឡើងចំនួន ៥២ គម្រោង ប៉ុន្តែ ផ្ទៃក្រឡាសរុបមានចំនួន ៤.៩៤ លានម៉ែត្រការ៉េ គឺបានធ្លាក់ចុះ ១១,៣ ភាគរយ ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ។ តាមការសង្កេត សកម្មភាពសាងសង់នៅតែបន្តកើនឡើងខ្ពស់ និងការ នាំចូលបរិក្ខាសម្រាប់គាំទ្រវិស័យសំណង់ បានកើនឡើងជាង ៤៣,៨ ភាគរយ ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន បើទោះបីជា សំណើសុំសាងសង់ថ្មីមានទំហំផ្ទៃក្រឡាថមថយក៏ដោយក្តី ។

៨. នៅខែតុលា ឆ្នាំ២០១៥ និន្នាការថ្លៃទំនិញសំខាន់ៗលើទីផ្សារអន្តរជាតិ មានដូចជា (១) **ថ្លៃប្រេងឆៅ**នៅលើទីផ្សារអន្តរជាតិសម្រាប់កិច្ចសន្យាលក់មួយខែខាងមុខ ជាមធ្យមបានកើនឡើងចំនួន ១,៥ ភាគរយ ។ Brent បានកើនឡើងចំនួន ១,៩ ភាគរយ Dubai បានកើនឡើង ០,៩ភាគរយ និង WTI បានកើនឡើងចំនួន ១,៧ ភាគរយធៀបទៅនឹងខែមុន ប៉ុន្តែ បានថយចុះ ៤៥,៤ ភាគរយ ធៀបនឹង១២ ខែមុន ។ តាមការសង្កេតបរិមាណផ្គត់ផ្គង់ប្រេងពិភពលោក មានការកើនឡើងធៀបទៅនឹងរយៈពេលដូចគ្នាឆ្នាំមុន ដែលកំណើននេះ គឺមកពីកំណើនការផលិតប្រេងក្នុងក្រុមប្រទេសសមាជិកជាពិសេស ប្រទេសអ៊ីរ៉ង់ ដែលត្រូវបានដកទណ្ឌកម្មសេដ្ឋកិច្ច និងក្រុមប្រទេសមិនមែនជាសមាជិក OPEC រួមទាំងការលក់គេចពន្ធរបស់ក្រុមផ្តាច់ខ្លួននៅក្នុងតំបន់មជ្ឈិមបូព៌ា។ (២)**ថ្លៃអង្ករ**អង្ករកម្ពុជាមានតម្លៃខ្ពស់ជាងអង្ករថៃ និងអង្ករវៀតណាមនៅលើទីផ្សារអន្តរជាតិ ដោយសារការកែឆ្នៃកាន់តែមានភាពល្អប្រសើរជាងមុន ដែលធានាបាននូវគុណភាពអង្ករ ព្រមទាំងការពង្រីកទីផ្សារកាន់តែមានភាពទូលំទូលាយ និងមានការជឿជាក់ពីអតិថិជន ។ ប៉ុន្តែ តម្លៃខ្ពស់នៅលើទីផ្សារធៀបនឹងប្រទេសមួយចំនួន ជាកិច្ចប្រឈមសមត្ថភាពប្រកួតប្រជែងនៅថ្ងៃខាងមុខ។ អង្ករថៃនាំចេញ (ខ្ទេច ៥ ភាគរយ) បានកើនឡើង ៤,៥ ភាគរយ ធៀបនឹងខែមុនឬធ្លាក់ចុះ ១២,៩ ភាគរយ បើធៀបនឹងខែដូចគ្នាឆ្នាំមុន និងអង្ករវៀតណាម (ខ្ទេច ៥ ភាគរយ) បានកើនឡើង ៤,៩០ ភាគរយ ធៀបទៅនឹងខែមុន ឬ បានធ្លាក់ចុះចំនួន ២១,៦ភាគរយ បើធៀបនឹងខែដូចគ្នាឆ្នាំមុន ។ ការកើនឡើងវិញបន្តិចនៃថ្លៃអង្ករនេះ គឺបណ្តាលមកពីកំណើនពីតម្រូវការ និងការសហការទីផ្សារដែគួសម្រាប់ការនាំចេញបានជោគជ័យ (៣)**ថ្លៃកៅស៊ូ** កៅស៊ូឆៅស្តង់ដារ TSR20[1] បានកើនឡើងចំនួន ០,៤ ភាគរយ ធៀបនឹងខែ

[1] កៅស៊ូTSR20: Technically Specific Rubber (ហៅបានម្យ៉ាងទៀតថា ISNR20: Indian Standards Naturally Rubber) ជាប្រភេកៅស៊ូដែលបានកែច្នៃក្នុងកម្រិតខ្ពស់ប្រើប្រាស់សម្រាប់ផលិតជាកង់ឡានបំពង់ទីបជ័រ កម្រាលជ័រ ស្បែកជើង អាវភ្លៀជាដើម។ កៅស៊ូប្រភេទនេះមានកម្រិតស្អិតទាប

មុន ប៉ុន្តែ បានថយចុះ ១៦,៨ ភាគរយធៀបនឹង១២ខែមុន។ កៅស៊ូឆៅស្តង់ដារ SGP/MYS(សឹង្ហបុរី-ម៉ាឡេស៊ី) បានធ្លាក់ចុះចំនួន ០,៩ ភាគរយ ធៀបនឹងខែមុននិង ៦,២ ភាគរយធៀបនឹង១២ខែមុន ទោះបីជា ផ្នែកផលិតកម្ម និងទីផ្សារមូលបត្រនៅក្នុងប្រទេសចិនប្រសើរឡើងវិញបន្តិចក្តី ។

*រៀបចំដោយ*

*នាយកដ្ឋានស្ថិតិ*

*អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ*

*ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ*

*Statistics Department*

*General Department of Economic and Public Finance Policy*

*Ministry of Economy and Finance*

---

ហើយងាយស្រួលលាយបញ្ចូលជាមួយសារធាតុដទៃទៀត ដែលធ្វើឱ្យផលិតផលដែលផលិតចេញពីកៅស៊ូនេះមានភាពរឹងមាំធន់ និងមិនងាយសឹករិចរិល។